# គោលការណ៍ណែនាំ ក្នុងពេលប្រឡងវិញ្ញាសាសរសេរ
# របស់អាហារូបករណ៍រដ្ឋាភិបាលជប៉ុន ឆ្នាំ២០២៧ (MEXT2027)

- សម្រាប់វេនព្រឹក បេក្ខជនត្រូវមកដល់មណ្ឌលប្រឡងចន្លោះម៉ោង7:00-7:30 ព្រឹក និងយឺតបំផុតត្រឹមម៉ោង7:40 ព្រឹក។ ករណីមកដល់ក្រោយនេះ បេក្ខជននឹងមិនអនុញ្ញាតឱ្យចូលបន្ទប់ប្រឡងទេ។
- សម្រាប់វេនរសៀល បេក្ខជនត្រូវមកដល់មណ្ឌលប្រឡងចន្លោះម៉ោង12:00-12:30 និងយឺតបំផុតត្រឹមម៉ោង12:40។ ករណីមកដល់ក្រោយនេះ បេក្ខជននឹងមិនអនុញ្ញាតឱ្យចូលបន្ទប់ប្រឡងទេ។
- បេក្ខជនត្រូវស្លៀកសំលៀកបំពាក់សមរម្យ។ សូមណែនាំបេក្ខជនគួរស្លៀកឯកសណ្ឋានសាលា។
- បេក្ខជនត្រូវបង្ហាញទៅកាន់អនុរក្សនូវបណ្ណសម្គាល់ខ្លួនដូចជាអត្តសញ្ញាណបណ្ណ ឬ កាតសិស្សជាដើម (ដូចពេលដាក់ពាក្យ)។
- បេក្ខជនអាចដាក់សម្ភារៈលើតុប្រឡងបានតែ ប៊ិច (ខ្មៅ ឬ ខៀវ) ខ្មៅដៃ ជ័រលុបប៉ុណ្ណោះ។
- សូមរក្សាសម្ភារៈដូចជាទូរស័ព្ទដៃ ម៉ាស៊ីនគិតលេខ នាឡិកាដៃអេឡិចត្រូនិច សៀវភៅ និងសម្ភារៈអេឡិចត្រូនិចផ្សេងៗទៀត អាហារ(ប្រអប់បាយ) នៅក្នុងកាបូប ឬ កាតាប ហើយទុកនៅផ្នែកខាងមុខនៃក្តារខៀន។
- ការទុកដាក់អាហារ (ប្រអប់បាយ) ត្រូវប្រាកដថាមិនមានក្លិនរំខានដល់អ្នកដទៃ។
- ទូរសព្ទដៃ និងនាឡិកាអេឡិចត្រូនិច ទោះបីជាបានទុកក្នុងកាបូបហើយក៏ដោយ ត្រូវប្រាកដថាបានបិទសម្លេង ឬ បិទតែម្តង ដើម្បីជៀសវាងមានសំឡេងរំខានពេលកំពុងប្រឡង។
- បេក្ខជនត្រូវតែចុះហត្ថលេខានៅលើក្រដាសវត្តមាន។
- បេក្ខជនមិនត្រូវជជែកគ្នាអំឡុងពេលប្រឡងជាដាច់ខាត។
- បេក្ខជនហាមលួចមើល ឬ ចម្លងពីអ្នកដទៃជាដាច់ខាត។
- អនុរក្សនឹងចែកក្រដាសវិញ្ញាសា៥នាទី មុនពេលចាប់ផ្តើមការប្រឡង ប៉ុន្តែបេក្ខជនមិនត្រូវប៉ះពាល់នោះទេ រហូតដល់លឺសម្លេងកន្តឹងបន្លឺឡើងទើបអាចចាប់ផ្តើមបើកបាន។
- ពេលបើកវិញ្ញាសាប្រឡង ដំបូងបង្អស់សូមសរសេរឈ្មោះ និងលេខតុ។
- រាល់ឯកសារដែលអនុរក្សចែកជូនទៅ ត្រូវតែប្រគល់មកវិញទាំងអស់។

- ៥នាទីមុនបញ្ចប់ការប្រឡង សម្លេងជួងនឹងត្រូវប្រកាសឡើងដើម្បីជាដំណឹងដល់បេក្ខជន។
- សម្លេងជួងនឹងបន្លឺឡើងពេលដល់ម៉ោងបញ្ចប់ការប្រឡង បេក្ខជនត្រូវទម្លាក់ ប៊ិច ឬ ខ្មៅដៃចុះ ហើយរងចាំរហូតដល់អនុរក្សប្រមូលវិញ្ញាសា និងអនុញ្ញាតឲ្យចេញក្រៅ ទើបអាចចេញពីបន្ទប់ប្រឡងបាន។
- បេក្ខជនមិនអាចចេញមុនពេលការប្រឡងបញ្ចប់ជាដាច់ខាត លើកលែងតែវិញ្ញាសាភាសាជប៉ុន ដោយបេក្ខជនត្រូវនៅឲ្យបានយ៉ាងហោចណាស់៣០នាទី។ បន្ទាប់ពីចាកចេញពីបន្ទប់ប្រឡង ហើយបេក្ខជនមិនអាចវិលត្រឡប់មកវិញបានទេ ហើយក៏មិនអាចនៅក្បែរបន្ទប់ ឬ អាគារប្រឡងជាដាច់ខាត។ បេក្ខជនត្រូវត្រឡប់ទៅវិញដោយស្ងៀមស្ងាត់ ជៀសវាងរំខានដល់បេក្ខជនដែលនៅបន្តការប្រឡងផ្សេងទៀត។
- បន្ទាប់ពីសម្រាកថ្ងៃត្រង់ បេក្ខជនត្រូវមកដល់មណ្ឌលប្រឡងចន្លោះម៉ោង12:00-12:30 ។ បេក្ខជនត្រូវបង្ហាញអនុរក្សម្តងទៀតនូវបណ្ណសម្គាល់ខ្លួនដូចជាអត្តសញ្ញាណបណ្ណ ឬ កាតសិស្សជាដើម (ដូចពេលដាក់ពាក្យ)។

សូមអរគុណ!